ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា


ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង វណ្ណៈ

២-មេធាវី អ៊ឹង គិរិយា

៣-មេធាវី កែត ឃី

៤-មេធាវី អ៊ីវ ប៊ុលី

៥-មេធាវី ខៀវ សំបូរ

៦-មេធាវី ជា សុកនួន

៧-មេធាវី សាន់ ជួយ

៨-មេធាវី ថាន ផានិត

៩-មេធាវី ជូ ចាន់ធីរ៉ា

១០-មេធាវី កេង សុម៉ាឡា

១១-មេធាវី ម៉ី ឧសភា

១២-មេធាវី សេង សុខឃីម

១៣-មេធាវី លីវ សុវណ្ណា

១៤-មេធាវី ឈីវ តិរម្យ

១៥-មេធាវី សំ សុគង់

១៦-មេធាវី នង មាននួ

១៧-មេធាវី អ៊ូ ធីតាពៅ

១៨-មេធាវី លី ពីង

១៩-មេធាវី យឹម វិសុត្រ

២០-មេធាវី លឹម ច័ន្ទលីដា

២១-មេធាវី កែ វិសាល

២២-មេធាវី ហូ លីហួវ

២៣-មេធាវី ទ៉ា ពិសី

២៤-មេធាវី ជា ហុងរី

២៥-មេធាវី សៅ កញ្ញា

២៦-មេធាវី ម៉ុន វិមានចំប៉ា

២៧-មេធាវី ឈី សម្បត្តិ


លេខ : ០០៣ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីឡើងវិញ

## ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥

-បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៧

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០

-បានឃើញសេចក្តីសម្រេចលេខ ០០៥/សសគម/១៤ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤ របស់គណៈមេធាវី ស្តីពីការលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី

-បានឃើញសេចក្តីសម្រេចលេខ ២៣៩/សសគម/១៥ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ របស់គណៈមេធាវី ស្តីពីការកែប្រែទណ្ឌកម្មជាបទវិន័យ

-បានឃើញលិខិត ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ របស់លោកមេធាវី **គួយ ធុនណា**។


អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨

ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

# ស ម្រេ ច

**ប្រការ ១.-** អនុញ្ញាតឱ្យលោកមេធាវី **គួយ ឆុនណា** អត្តលេខ **៦៩៤** **ចូលប្រកបវិជ្ជាជីវៈមេធាវីឡើងវិញ ចាប់ពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦** នេះតទៅ។

**ប្រការ ២.-** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣.-** អគ្គលេខាធិការ អគ្គហេរញ្ញិក និងសាមីខ្លួន ត្រូវអនុវត្តសេចក្ដីសម្រេចនេះ តាមមុខការរៀងៗខ្លួន ៕

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

**មេធាវី.ប៊ុន-ហុន**

**ចម្លងជូនៈ**

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ក្រុមប្រឹក្សាគណៈមេធាវី

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៣

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី

នៃព្រះរាជាណាចក្រកម្ពុជា

04/01/16

ប៊ុន ណាវីណា

04-01-16

សាន សុធន

05-01-16

មេធាវី.ប៊ុន-ហ្វុង

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
ចូល
-លេខ: ០០៥
-ម៉ោង: ១១.០០
-ថ្ងៃ ខែ ឆ្នាំ: ០៤.០១.១៦
-បញ្ជូន:

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

****

## ពាក្យស្នើសុំប្រកបវិជ្ជាជីវៈមេធាវី

ខ្ញុំបាទឈ្មោះ **គួយ ធុនណា** អក្សរឡាតាំង KOUY THUNNA ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ៦៩៤ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ២៧ ផ្លូវលេខ១០០៧ ក្រុមទី៥ ភូមិពោងពាយ ឃុំ/សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**លោកប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** សំណើសុំប្រកបវិជ្ជាជីវៈមេធាវីឡើងវិញ ។

**យោង** ៖ -ព្រះរាជក្រមលេខ នស/ រកម / ០៨៩៥ /០៦ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

-សេចក្តីសម្រេចលេខ ២៣៩/សសគម/១៥ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែប្រែទណ្ឌកម្មជាបទវិន័យ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា ៖ ដោយខ្ញុំបាទត្រូវបានអនុវត្តទណ្ឌកម្មហាមឃាត់ប្រកបវិជ្ជាជីវៈរយពេល២ឆ្នាំ ដូចមានចែងក្នុងប្រការ២នៃសេចក្តីសម្រេចលេខ២៣៩/ សសគម/១៥ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ចប់ជាស្ថាពរ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦នេះ ខ្ញុំបាទសូម **លោកប្រធាន** មេត្តាអនុញ្ញាតអោយខ្ញុំបាទបានប្រកបវិជ្ជាជីវៈមេធាវីឡើងវិញ ដោយក្តីអនុគ្រោះ ។

សូម **លោកប្រធាន** មេត្តាទទួលនូការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ,ថ្ងៃទី04 ខែមករា ឆ្នាំ២០១៦

**ហត្ថលេខា**

**សូមភ្ជាប់ជូនមកជាមួយ**

-សេចក្តីសម្រេចលេខ ២៣៩/សសគម/១៥ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែប្រែទណ្ឌកម្មជាបទវិន័យ (ថតចម្លង) ។

- ប័ណ្ណសំគាល់មេធាវី(ថតចម្លង) ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា


**ប្រធានគណៈមេធាវី**

មេធាវី ប៊ុន ហុន

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី ង៉ា ចូនគា

២-មេធាវី កែវ ជា

៣-មេធាវី ហាក់ សៀកលី

៤-មេធាវី ចំរួន ទិចិត្រ

៥-មេធាវី ចេង ប៉េងហាប់

៦-មេធាវី ជួង ជូងី

៧-មេធាវី លី ចន្ទតុលា

៨-មេធាវី តែ ចំណាន

៩-មេធាវី វិច សុធាថា

១០-មេធាវី ពេជ្រ សូរិយា

១១-មេធាវី គង់ ទីលីន

១២-មេធាវី យុង ផានិត

១៣-មេធាវី លឹម វណ្ណា

១៤-មេធាវី សុក ស៊ីផាន់ណា

១៥-មេធាវី ស្រ៊ុ គឹមយូ

១៦-មេធាវី គុយ នាម

១៧-មេធាវី នូច ធីរិទ្ធ

១៨-មេធាវី គឹម សាសនា

១៩-មេធាវី សួស សារឿន

២០-មេធាវី ទូន មករា

២១-មេធាវី លឹម អេងគេនៈ

២២-មេធាវី ហុង គឹមសួន

២៣-មេធាវី ឯក ធាលា

២៤-មេធាវី ឡុង ជាក់

២៥-មេធាវី សួង ចាន់ថន

២៦-មេធាវី ស សុធាន

២៧-មេធាវី លៀន ចិន្តា


លេខ : ៤៣៩ /សសគម/១៥

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥

# សេចក្តីសម្រេច

## ស្តីពី

## ការកែប្រែទណ្ឌកម្មជាបទវិន័យ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៧
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញសេចក្តីសម្រេចលេខ ០០៥/សសគម/១៤ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញដីកាសម្រេចលេខ ២៣៥ "ឃ" ដស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ របស់តុលាការកំពូល
- បានឃើញលិខិតលេខ ៤២៧/១៥ តកក-សររ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ របស់តុលាការកំពូល បញ្ជាក់ការចូលស្ថាពរនៃដីកាសម្រេចលេខ ២៣៥ "ឃ" ដស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ របស់តុលាការកំពូល
- បានឃើញលិខិតរបស់លោក គួយ ធុនណា ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥

- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥

## សម្រេច

**ប្រការ ១.-** ត្រូវបានលុបសេចក្តីសម្រេចលេខ ០០៥/សសគម/១៤ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-** ត្រូវបានហាមឃាត់លោកមេធាវី **គួយ ធុនណា** អត្តលេខ ៦៩៤ ប្រកបវិជ្ជាជីវៈមេធាវីរយៈពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦។

**ប្រការ ៣.-** លោកមេធាវី **គួយ ធុនណា** ពុំអាចប្រកបវិជ្ជាជីវៈមេធាវីបានទេ ប៉ុន្តែត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី។

**ប្រការ ៤.-** ក្នុងរយៈពេលហាមឃាត់នេះ លោកមេធាវី **គួយ ធុនណា** ត្រូវអនុវត្តកាតព្វកិច្ចទាំងអស់ចំពោះគណៈមេធាវី ដូចជាសមាជិកគណៈមេធាវីដទៃទៀតដែរ។

**ប្រការ ៥.-** អគ្គលេខាធិការ អគ្គហេរញ្ញិក និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួន៕

**ប្រធាន**

**មេធាវី. ប៊ុន ហុន**

**ចម្លងជូន :**

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
-សមាជិកក្រុមប្រឹក្សាគណៈមេធាវី
-ដូចប្រការ ៥
-ឯកសារ-កាលប្បវត្តិ

**THE BAR ASSOCIATION**
**OF THE KINDOM OF CAMBODIA**

LAWYER'S IDENTITY CARD



**ID: 694**

**Name: KUOY THUNNA**

**Occupation: Attorney-at-law**

**Date of Expire: 31 ... ber 2016**

**Date of Issue ... 2015**

**President**

**BUN HONN**

**Address: Building at conner of St. 1129 & St.1930, S/K Phnom Penh Thmey, Khann Sen Sok, Phnom Penh**

**គណៈមេធាវី**
**នៃព្រះរាជាណាចក្រកម្ពុជា**

**ប័ណ្ណសម្គាល់មេធាវី**



**អត្តលេខ៖ ៦៩៤**

នាមត្រកូល និងនាមខ្លួន ៖ **គួយ ធុនណា**

មុខងារ ៖ **មេធាវី**

ផុតកំណត់ថ្ងៃទី ៣... ឆ្នាំ ២០១៦

ចេញថ្ងៃទី ០១ ... ២០១៥

...ធាន

**ប៊ុន ហុន**

អាសយដ្ឋាន៖ អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និង ១៩៣០ សង្កាត់ ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
ចូល
-លេខ: 1537
-ម៉ោង: 8:20
-ថ្ងៃ ខែ ឆ្នាំ: 01-7-15
-បញ្ជូន:

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទឈ្មោះ **គួយ ធុនណា** អតីតសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ៦៩៤ មានអាសយដ្ឋានផ្ទះលេខ២៧ ផ្លូវ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**លោក ម៉ឺន ហ៊ិន ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**និង សមាជិក សមាជិកាក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុៈ** សំណើសុំក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និង សម្រេចបន្ធូរបន្ថយទណ្ឌកម្មដល់រូបខ្ញុំបាទឡើងវិញ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូន**លោកប្រធាន** និង **សមាជិក សមាជិកា**មេត្តាជ្រាបថា ៖ ខ្ញុំបាទមានការសោកស្ដាយនូវកំហុសឆ្គងដែលរូបខ្ញុំបានប្រព្រឹត្តកន្លងមក ។ ដើម្បីអោយរូបខ្ញុំមានឱកាសប្រកបវិជ្ជាជីវៈមេធាវីឡើងវិញ ខ្ញុំស្នើសុំ**លោកប្រធាន** និង **សមាជិក សមាជិកាក្រុមប្រឹក្សាគណៈមេធាវី**ផ្ដល់ការអនុគ្រោះធ្វើការពិនិត្យ និង សម្រេចបន្ធូរបន្ថយទណ្ឌកម្មអោយខ្ញុំបាទដោយក្ដីអនុគ្រោះ ។

បើរូបខ្ញុំបាទមានឱកាសប្រកបវិជ្ជាជីវៈមេធាវី ខ្ញុំសូមសន្យាថានឹងប្រតិបត្តិអោយបានត្រឹមត្រូវតាមវិធាននៃវិជ្ជាជីវៈមេធាវី ។

ខ្ញុំសូមអរគុណ និង សំដែងនូវការដឹងគុណយ៉ាងជ្រៀលជ្រៅ និង ស្មោះជាទីបំផុតចំពោះ**លោកប្រធាន** និង **សមា ជិក សមាជិកានៃក្រុមប្រឹក្សាគណៈមេធាវី** ។

សូម**លោកប្រធាន** និង **សមាជិក សមាជិកានៃក្រុមប្រឹក្សាគណៈមេធាវី**មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥

**ហត្ថលេខា**

**គួយ ធុនណា**

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
ចូល
-លេខ: 2212
-ម៉ោង: 2:10
-ថ្ងៃ ខែ ឆ្នាំ: 24-12-14
-បញ្ជូន:

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតសុំទោស

ខ្ញុំបាទឈ្មោះ **គួយ ធុនណា** អតីតសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រមកម្ពុជា អត្តលេខ ៦៩៤ មានអាសយដ្ឋានផ្ទះលេខ២៧ ផ្លូវ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**លោកមេធាវី ប៊ុន ហ៊ុន ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**
**និង សមាជិក សមាជិកានៃក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** សំណើសុំការសណ្តោសប្រណីអនុគ្រោះពី**លោកប្រធាន** និង **សមាជិក សមាជិកាក្រុមប្រឹក្សាគណៈមេធាវី** ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូន**លោកប្រធាន** និង **សមាជិក សមាជិកា** មេត្តាជ្រាបថា ៖ ខ្ញុំបាទសូមទទួលស្គាល់កំហុសទាំងស្រុងដែលបានប្រព្រឹត្ត ដោយសារតែខ្ញុំមិន ទាន់យល់ច្បាស់អំពីក្រមសីលធម៌វិជ្ជាជីវៈមេធាវី និង ដោយសារការបកស្រាយខុសនៃបណ្តាណសារព័ត៌មាន មួយចំនួន ។ ខ្ញុំមានការសោកស្តាយ និង មានវិប្បដិសារីយ៉ាងខ្លាំង ហើយនេះជាមេរៀនដើម្បីអោយខ្ញុំយល់ដឹ ងថែមទៀតពីក្រមសីលធម៌វិជ្ជាជីវៈមេធាវី ។ ខ្ញុំនឹងចងចាំនូវបទពិសោធន៍នេះ ដើម្បីប្រែក្លាយខ្លួនអោយទៅជា មេធាវីល្អថ្ងៃអនាគត ។

ខ្ញុំសូម **លោកប្រធាន** និង **សមាជិក សមាជិកានៃក្រុមប្រឹក្សាគណៈមេធាវី** មេត្តាយោគយល់សណ្តោសប្រណីនូវទោសកំហុសទាំងនេះដល់រូបខ្ញុំបាទដោយអនុគ្រោះ និង មេត្តាអនុញ្ញាតអោយខ្ញុំបាទបានចូលប្រកបវិជ្ជាជីវៈជាមេធាវីសាជាថ្មីឡើងវិញផង ហើយខ្ញុំសូមសន្យាថានឹងមិនធ្វើអោយមានកំហុសឆ្គង ដូចនេះទៀតជាដាច់ខាត ។

ខ្ញុំសូមសំដែងការដឹងគុណយ៉ាងជ្រៀលជ្រៅ និង ស្មោះជាទីបំផុត ចំពោះ**លោកប្រធាន** និង **សមា ជិក សមាជិកានៃក្រុមប្រឹក្សាគណៈមេធាវី** ។

សូម**លោកប្រធាន** និង **សមាជិក សមាជិការនៃក្រុមប្រឹក្សាគណៈមេធាវី**មេត្តាទទួលនូវ ការគោរព ដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤

**ហត្ថលេខា**

25-12-14

25-12-14

**សាង សុធន**

មេធាវី. ប៊ុន_ហ៊ុន